# ឋ

**ឋ** ព្យញ្ជនៈ ទី ២ ក្នុងវគ្គទី ៣ ជាមុទ្ធជៈ មានសំឡេងកើតក្នុងក្បាល និងមានសំឡេងលាន់ឮទៅខាងក្បាល ស្មើគ្នានឹងសំឡេង ថ ទន្តជៈ ដែលឮស្ងួរចេញត្រង់ប្រទាល់ធ្មេញ, សំ. បា. ជា ឋ: ឬ ឋ̣: ស្ងួរជាមុទ្ធជៈ, ស្មើគ្នានឹង ថ: ទន្តជៈ, ជាធនិតអឃោសៈ, ខាង សំ. បា. គ. បំ. ឋ: ឋ̣: ឬ ថ: ថ̣: (បើកមាត់ឈោងចុងអណ្ដាតទៅខាងលើ, កុំឲ្យដូច ថ: ថ̣: ដែលឈោងចុងអណ្ដាតឲ្យទះត្រង់ប្រទាល់ធ្មេញ) ។ ប៉ុន្តែខាងភាសាខ្មែរយើង អានឮ ឋ ថ ដូចគ្នា ។

**ឋបនកម្ម** (ឋៈ-ប៉ៈ-ន៉ៈ-កំ) ន. (បា.) កម្មគឺការតម្កល់ទុកនូវអ្វីៗ; ដំណើរដែលគេរៀបចំតាក់តែងឡើង, ការធ្វើអ្វីមួយឲ្យកើតឡើងហើយតម្កល់តាំងទុកឲ្យបានឋិតថេរតទៅ: *ឋបនកម្មនៃយន្តតម្បាញ គេបានធ្វើរួចស្រេចហើយ ។*

**ឋបនាការ** (ឋៈ-ប៉ៈ-ណាកា) ន. (បា.; សំ. *ស្ថាបនាការ*) ការដែលឋិត, ដែលតាំង, ដែលតម្កល់នៅ: *ឋបនាការកើតចេញមកញុំប្រទីបការនៅក្រុងព្រះសីហនុ ។*

**ឋបនីយកណ្ឌ** (ឋៈ-ប៉ៈ-ណី-យ៉ៈ-ក័ន) ន. (បា.; សំ. *ស្ថាបនីយកណ្ឌ*) របស់, ទ្រព្យ ដែលគួរតម្កល់ទុក, គួរតាំងទុក, ដែលត្រូវទុកដាក់: *គ្រឿងឧបករណ៍នេះជាឋបនីយកណ្ឌ ត្រូវទុកដាក់ឲ្យល្អ ។*

**ឋបនីយវត្ថុ** (ឋៈ-ប៉ៈ-ណី-យ៉ៈ-វ័ត-ថុ) ន. (បា.; សំ. *ស្ថាបនីយវស្តុ*) វត្ថុដែលគួរតាំងទុក, ដែលត្រូវតម្កល់ទុក: *ចុះគុនីកើតចេញយើងមានឋបនីយវត្ថុគ្រប់គ្រាន់ទេ?*

**ឋបនោកាស** ន. (បា.) កន្លែងទំនេរសម្រាប់ដាក់, សម្រាប់ទុករបស់ផ្សេងៗ: *ទីនេះធំណាស់ ឥតមានឋបនោកាសទេ ។*

**ឋបនោបាយ** ន. (បា.) ឧបាយ, គំនិត ដោះទុក ដោះដាក់...: *មានឋបនោបាយល្អ ។*

**ឋាន** ន. (បា.; សំ. *ស្ថាន*) ទី, កន្លែង, តំបន់, ប្រទេស, ទីតាំង, ទីតម្កល់ ។ល។: *ឋានមនុស្ស, ឋានសួគ៌, ឋានព្រហ្ម; នៅឋានណា? មកពីឋានណា?* ។ ពួកខ្មែរចដែលលាយឡំទ្វាសំព័ណ៌: *ឋានស, ឋានលឿង...* ។ ពួកខ្មែរគ្រឿងរចនា ត្រង់ដែលឆប ដែលលើង: *ក្រោមកម្ពស់គ្របកល្បូក ត្រូវទុកឲ្យមានឋានទំហំ ៤ ធ្នាប់ ។*



**ឋានៈ** (-នៈ) ន. (បា. *ឋាន*; សំ. *ស្ថាន*) ហេតុ, ដំណើរ, ទំនង: *សេចក្ដីនេះមានឋានៈគួរឲ្យជឿបាន ។* ងារ, បុណ្យងារ, ថ្នាក់ងារ, ថ្នាក់ស័ក្តិយស: *លោកមានឋានៈជាអ្វី? —មានឋានៈជាមន្ត្រីលេខាធិការក្រសួងសង្គមកិច្ច; គួរកុំប្រកាន់ឋានៈពេក ។*

**ឋានន្តរ** (ឋាន់-ន៉ៈ-ត: ឬ ឋាន់-ន-តរ) ន. (បា.) លំដាប់នៃទី, បុណ្យងារ, ងារ, ថ្នាក់ងារ, ថ្នាក់ស័ក្តិយស: *លោកមានឋានន្តរជាអ្វី? — មានឋានន្តរជាអភិបាលស្រុក, ឋានន្តរជាព្រះចៅម្រើនសម្បត្តិ ។*

**ឋានន្តរសក្តិ** ឬ —ស័ក្តិ (ឋាន់ន: រ៉ៈ-ស័ក) ន. (បា. សំ.; សំ. *ស្ថានន្តរ + សក្តិ*) អំណាចតាមបុណ្យងារ, បណ្ដាស័ក្តិធំតូចតាមបុណ្យងារ: *អគ្គីយការឋានន្តរស័ក្តិ* (ម. ព. *សក្តិ* ឬ *ស័ក្តិ* ផង) ។

**ឋានបក្ខ** (ឋាន់ៈបក់) ន. (បា. សំ.; បា. *ឋាន + បក្ខ*; សំ. *ស្ថាន* "ទី, ទីតម្កល់ + *បក្ខ* "ស្លាប") ពាក្យនេះខ្មែរយើងពីបុរាណ ប្រើជាឈ្មោះក្បាច់គ្របកល្បូកផ្កាប់ផ្ការ ដែលរចនាធ្វើជាលើង, ជាប្រដាប់ ទ្រព្រះពុទ្ធរូបឬទេវរូប: គ្របកល្បូកដែលសំយុងចុះមកក្រោម ហៅថា *ល្បូកផ្កាប់*; ដែលផ្ការឡើង ហៅថា *ល្បូកផ្ការ*; ទោះមានតែល្បូកផ្កាប់ ឬមានតែល្បូកផ្ការក្ដី ឬក៏មានគ្រប់តាំងផ្កាប់តាំងផ្ការក្ដី ហៅថា *ឋានបក្ខ* បានទាំងអស់: *ឋានបក្ខទ្រព្រះពុទ្ធរូប, ឋានបក្ខទេវរូប ។*

**ឋានប្បភេទ** (ឋាន់ប៉-ប៉ៈ-ភេទ) ន. (បា.; សំ. *ស្ថានប្រភេទ*) សេចក្ដីផ្សេងនៃទី, នៃហេតុ, នៃដំណើរ; ការចែក, បំបែកហេតុឬដំណើរ កំណត់ចំនួនប៉ុណ្ណេះប៉ុណ្ណោះ: *ធម៌នេះមានឋានប្បភេទ ១០ យ៉ាង ។*

**ឋានភាព** (ឋាន់ៈភាប) ន. ភាពនៃឋានៈ, ដំណើរ ទំនង, លក្ខណៈ, ជាន់ថ្នាក់: *ជនទាំងនោះ មានឋានភាពខ្ពង់ខ្ពស់, ឋានភាពនៃគ្រួសារ, ឋានភាពនៃជីវិត ។*

**ឋានានុក្រម** (ឋា-ណា-នុ-ក្រំ) ន. (បា. សំ.; បា. *ឋាន + អនុក្កម > ឋានានុក្កម*; សំ. *ស្ថាន + អនុក្រម > ស្ថានានុក្រម*) លំដាប់ឬរបៀប នៃទី, នៃងារ, នៃបុណ្យងារ, នៃស័ក្តិយស ។ ក្នុងកម្ពុជប្រទេសយើង ប្រើពាក្យនេះជាតំណែងនៃសមណស័ក្តិថ្នាក់តូចជាងរាជាគណៈ តាមលំដាប់ចុះមក: *និមន្តព្រះភិក្ខុសង្ឃរាជាគណៈ: ឋានានុក្រម ៦០ រូបចាប់ម្រើនព្រះបរិត្ត ។*

**ឋានានុរូប** (ឋា—) គុ. ឬ ន. (បា.; សំ. *ស្ថានានុរូប*) ដែលសមគួរតាមទី, តាមបុណ្យងារ...: ដំណើរ

សមគួរល្មមតាមទំ, តាមជាន់ថ្នាក់ : *ប្រព្រឹត្តតាមឋានានុរូប, អង្គុយតាមឋានានុរូប, កាន់ការតាមឋានានុរូប* ។

**ឋានីយ** (–នីយ ឬ –ណី) *ន.* (បា.; សំ. *ស្ថានីយ*) ទីសម្រាប់សម្នាក់, ទីសំចត, ទីចត, ដំណាក់សម្រាប់ឈប់សម្រាក, សម្រាប់ចាក់ចេញជាដើម; ភូមិ, ស្រុក ។ល។ : *ឋានីយរទេះ, ឋានីយរថយន្ត, ឋានីយរទេះភ្លើង* ... (ច្រើនប្រើ *ស្ថានីយ* ជាង *ឋានីយ*) ។

**ឋិត** *គុ.* (បា.; សំ. *ស្ថិត*) តម្កល់, តាំង, តាំងនៅ, នៅ, ឈរ ... (ពាក្យខ្លះច្រើនប្រើ *ស្ថិត* ជាង *ឋិត*) : *ព្រះមហាក្សត្រិយ៍ទ្រង់ព្រះស្ថិតក្នុងព្រះមហាប្រាសាទ* (ម. ក. *សណ្ឋិត* ទៀតផង) ។

**ឋិតថេរ** *គុ.* (បា. *ឋិត + ថិរ*; សំ. *ស្ថិត + ស្ថិរ*) ដែលឋិតនៅយូរ, ទៀងនៅ, ដែលតាំងនៅមាំមួន, ខ្ជាប់ខ្ជួន; ដែលជាប់បានយូរ; ស្ថាពរ : *របស់ឋិតថេរ, ការងារឋិតថេរ* ។ *កិ. វិ.* ដែលមានជាប់យូរមកហើយ មិនដែលដាច់, មិនដែលឈប់ : *ធ្វើការឋិតថេរ* ។

**ឋិតថេរចិរកាល** (–ចេរកាល) *ន.* (បា. *ឋិត + ថិរ + ចិរ + កាល*) កាល, គ្រាដែលឋិតថេរយឺនយូរ (ម. ក. *ឋិតថេរ* និង *ចិរកាល* ទៀតផង) ។

**ឋិតិ** *ន.* (បា.; សំ. *ស្ថិតិ*) ទីតាំង, ជីវិត, ដំណើររស់នៅ; ដំណើរតាំងនៅនៃចិត្ត ... ។ *ឋិតិ* ឬ *ស្ថិតិ* បញ្ញ ។

**ឋិតិកាល** *ន.* (បា.; សំ. *ស្ថិតិកាល*) កាល, គ្រាដែលតាំងនៅ; កាលនៃការឋិតនៅ ... ។

**ឋិតិភាព** (–ភាព) *ន.* (បា. *ឋិតិភាវ*; សំ. *ស្ថិតិភាវ*) ភាពនៃការឋិតនៅ, ដំណើរដែលឋិតនៅ ... ។